ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ : ០៦០ សាសារ.

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលសមាសភាពក្រុមការងារតាមដានស្រង់ព័ត៌មានប្រចាំថ្ងៃ ពីបណ្តាញទំនាក់ទំនងសង្គមផ្លូវការរបស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងសេចក្តីសម្រេចលេខ ០២៨ ដនស/សសរ ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួលសមាសភាពក្រុមការងារតាមដានស្រង់ព័ត៌មានប្រចាំថ្ងៃពីបណ្តាញទំនាក់ទំនងសង្គមផ្លូវការរបស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**ប្រការ ១.-**

កែសម្រួលសមាសភាពក្រុមការងារតាមដានស្រង់ព័ត៌មានប្រចាំថ្ងៃពីបណ្តាញទំនាក់ទំនងសង្គមផ្លូវការរបស់ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ដែលមានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| ១. ឯកឧត្តម **លាង មុនីរិទ្ធ** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **ឡៅ និពូសីហា** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣. លោក **តួន សោភា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៤. លោក **សួន សុផា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ | សមាជិក |

| | | |
|---|---|---|
| ៥. លោក **ច្រាក់ អច្ចារ៉ា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានលំនៅឋាន | សមាជិក |
| ៦. លោក **ម៉េង ម៉ុណ្ណារិទ្ធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម | សមាជិក |
| ៧. លោក **អ៊ុត សំអាន** | អគ្គាធិការរងនៃអគ្គាធិការដ្ឋាន | សមាជិក |
| ៨. លោក **ជាមសុផល មករា** | ប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៩. លោកស្រី **នូសុវត្តិ ចាន់វត្តី** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគ និងទំនាក់ទំនងអន្តរជាតិ | សមាជិកា |
| ១០. លោក **ជិន វណ្ណចន្ទ** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ | សមាជិក |
| ១១. លោក **សំរិទ្ធ សុចិត្រា** | អនុប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |
| ១២. លោក **អន ម៉ុនថន** | មន្ត្រីនាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគ និងទំនាក់ទំនងអន្តរជាតិ | លេខាកត់ត្រា |
| ១៣. លោក **រ៉េន ប្រិមប្រិយ** | មន្ត្រីជាប់កិច្ចសន្យា | លេខាកត់ត្រា |

**ប្រការ ២._**

ក្រុមការងារនេះមានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- តាមដាន និងស្រង់ព័ត៌មានប្រចាំថ្ងៃ និងសំណូមពរនានារបស់ប្រជាពលរដ្ឋដែលមានក្នុង Facebook Page ផ្លូវការរបស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី Facebook https://www.facebook.com/hunsencambodia ដែលពាក់ព័ន្ធនឹងវិស័យការងាររបស់ក្រសួង
- បែងចែកសំណូមពរនានាដែលស្រង់បានខាងលើ ជូនអង្គភាព ឬអ្នកពាក់ព័ន្ធ ដើម្បីឆ្លើយបំភ្លឺ ឬមានវិធានការដោះស្រាយទាន់ពេលវេលា
- ធ្វើរបាយការណ៍ប្រចាំថ្ងៃជូនក្រសួង
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់ក្រសួង។

**ប្រការ ៣._**

សមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្រុមការងារនេះមានសិទ្ធិប្រើប្រាស់មន្ត្រីរាជការក្រោមឱវាទឱ្យជួយការងារតាមការចាំបាច់។

**ប្រការ ៤._**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៥._**

នាយកខុទ្ទកាល័យ គ្រប់អគ្គនាយក អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានរាយនាមក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១២ រោច ខែ ស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៨

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

ជា សុផារ៉ា

**កន្លែងទទួល ÷**

- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងព័ត៌មាន
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ